**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**លេខ...០៣/១៧..នព**

## សេចក្ដីប្រកាសព័ត៌មាន
## អ្នកនាំពាក្យ ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា

អ្នកនាំពាក្យក្រសួងការពារជាតិ សូមជម្រាបជូនសាធារណៈជនជ្រាបថាទាហានមួកខៀវកម្ពុជា៣រូបដែលបានបាត់ខ្លួនក្រោយព្រឹត្តិការណ៍បាញ់ប្រហារ ដោយក្រុមឧទ្ទាមនៅសាធារណរដ្ឋអាហ្វ្រិកកណ្ដាល កាលពីយប់ថ្ងៃទី៨ខែឧសភាឆ្នាំ២០១៧ ពេលនេះបានស្លាប់ហើយ បន្ទាប់ពីសាកសពកម្លាំងកម្ពុជាទាំង៣ត្រូវបានរកឃើញនាព្រឹកថ្ងៃទី៩ ខែឧសភា ចម្ងាយប្រមាណ ២គ.ម.ពីកន្លែងកើតហេតុ ដោយមានការជួយអន្តរាគមន៍ពីក្រុមគ្រូព្រះវិហារនៅក្បែរនោះ សពទាំង៣ក៏ត្រូវបាននាំយកមកតម្កល់ទុកនៅតំបន់ ( Bangassou ) រង់ចាំបញ្ជូនតាមឧត្ថម្ភាគចក្រ.អ.ស.ប. មកកាន់ទីក្រុង (Bangui) ។

អ្នកនាំពាក្យក្រសួងការពារជាតិ សូមបញ្ជាក់ថា នៅយប់ថ្ងៃទី៨ខែឧសភា ឆ្នាំ ២០១៧ វេលាម៉ោង ៨:00 (ត្រូវនឹងម៉ោង២ទៀបភ្លឺ ថ្ងៃទី៩ ខែឧសភា ឆ្នាំ ២០១៧ នៅភ្នំពេញ) មានការពួនស្ទាក់វាយប្រហារដោយក្រុមឧទ្ទាមទៅលើក្បួនយុទ្ធដំណើរកងម្លាំង MINUSCA .របស់អ.ស.ប.បណ្ដាលឲ្យកម្លាំងមួកខៀវកម្ពុជាពលីនៅនឹងកន្លែងម្នាក់, របួសម្នាក់, និង៣នាក់ទៀតបាត់ខ្លួន ប៉ុន្តែអ្នកបាត់ខ្លួនទាំង៣នោះ ពេលនេះបានស្លាប់ ហើយការស្លាប់ចុងក្រោយនេះបានធ្វើឲ្យចំនួនពលីរបស់កងកម្លាំងមួកខៀវកម្ពុជាកើនឡើងដល់៤នាក់ ដែលក្នុងនោះរួមមាន៖

១.លោកពលបាលឯក (អនុសេនីយ៍ទោ) អ៊ឹម សំ បុគ្គលិកបើកបរប៊ុលដូស៊ែរ

២.លោកអនុសេនីយ៍ត្រី ( ព្រិន្ទបាលទោ ) ស៊ាង នរិន្ទ ជំនួយការត្រួតពិនិត្យគុណភាព

៣.លោកពលបាលឯក ( ព្រិន្ទបាលទោ ) មុំ តុលា ជំនួយការបើកបរអិចស្កាវ៉ាទ័រ

៤.លោកអនុសេនីយ៍ត្រី ( អនុសេនីយ៍ឯក ) ម៉ៅ អេង បុគ្គលិកពេទ្យ

ក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា សូមសម្ដែងនូវការសោកស្ដាយជាពន់ពេកនិងសូមចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំជាមួយក្រុមគ្រួសារនៃសព ចំពោះការពលីជីវិតប្រកបដោយកិត្តិយសថ្លៃថ្នូរ និងវិរភាពដ៏អង់អាចក្លាហាន នៃកងយោធពលខេមរភូមិន្ទ ដែលបានលះបង់ជីវិតក្នុងការបំពេញបេសកកម្មមនុស្សធម៌អន្តរជាតិក្រោមឆ័ត្រអ.ស.ប.នៅសាធារណៈរដ្ឋអាហ្វ្រិចកណ្ដាល៕

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១០ខែឧសភា ឆ្នាំ ២០១៧*

វិថីហ្សកឌឺមីត្រូវ សង្កត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤ អ៊ីម៉ែល៖ generalsec@mod.gov.kh